**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៚៛៚៚

**រដ្ឋបាលខេត្តព្រះសីហនុ**

លេខ:.០០៤./២១សណន

# សេចក្ដីណែនាំ

## ស្ដីពី

## ការផ្អាកលក់គ្រឿងស្រវឹងគ្រប់ប្រភេទរយៈពេល ១៤ថ្ងៃ ចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ

ស្ថិតក្នុងស្ថានភាពនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍«សហគមន៍ ២០ កុម្ភៈ» កាន់តែខ្លាំងឡើងៗ និងក្នុងគោលបំណងធានាការពារដល់អាយុជីវិតរបស់បងប្អូនប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្ដាប់ធ្នាប់សង្គម រដ្ឋបាលខេត្តព្រះសីហនុ សូមធ្វើការណែនាំដូចខាងក្រោម៖

១-ផ្អាកការលក់ដូរ ចែកចាយគ្រឿងស្រវឹងគ្រប់ប្រភេទ (ស្រាបៀរ និងស្រាគ្រប់ប្រភេទ) នៅក្នុងភូមិសាស្ត្រខេត្តព្រះសីហនុទាំងមូល ជាបណ្ដោះអាសន្ន ចាប់ពីថ្ងៃចេញសេចក្ដីណែនាំនេះតទៅ

២-គ្រប់ផ្សាររដ្ឋ ផ្សារឯកជន និងផ្សារម៉ាត ព្រមទាំងដេប៉ូចែកចាយគ្រឿងស្រវឹងគ្រប់ប្រភេទ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ ត្រូវផ្អាកជាបណ្ដោះអាសន្ននូវការលក់ដូរ ចែកចាយគ្រឿងស្រវឹងគ្រប់ប្រភេទ

៣-គ្រប់ភោជនីយដ្ឋាន អាហារដ្ឋាន តូបអាហារ ហាងកាហ្វេ ហាងភេសជ្ជៈ អាជីវកម្មដ្ឋានផ្នែកអាហារ-ភេសជ្ជៈ និងអាជីវករ អ្នកលក់ដូរ អ្នកចែកចាយគ្រឿងស្រវឹងគ្រប់ប្រភេទត្រូវផ្អាករាល់ការបម្រើគ្រឿងស្រវឹងជូនភ្ញៀវជាបណ្ដោះអាសន្ន។

ក្នុងករណីបងប្អូនប្រជាពលរដ្ឋ អ្នកគ្រប់គ្រងផ្សារ អ្នកគ្រប់គ្រងក្រុមហ៊ុន ម្ចាស់ដេប៉ូចែកចាយ ម្ចាស់ហាង ម្ចាស់តូបលក់ដូរ ក៏ដូចជាម្ចាស់ទីតាំងនានាពាក់ព័ន្ធការលក់ដូរគ្រឿងស្រវឹងដូចបានរៀបរាប់ខាងលើ មិនអនុវត្តតាមសេចក្ដីណែនាំនេះ ត្រូវទទួលការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ជាធរមាន ដោយគ្មានការលើកលែងឡើយ។

ទទួលបានសេចក្ដីណែនាំនេះ នាយករដ្ឋបាលសាលាខេត្ត ស្នងការដ្ឋាននគរបាលខេត្ត បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត មន្ទីរ អង្គភាពពាក់ព័ន្ធ រដ្ឋបាលក្រុង ស្រុក ឃុំ-សង្កាត់ គណៈកម្មការគ្រប់គ្រងផ្សារ ម្ចាស់ក្រុមហ៊ុន ម្ចាស់ដេប៉ូ ម្ចាស់អាជីវកម្មលក់ដូរគ្រប់ប្រភេទ អាជីវករ និងបងប្អូនប្រជាពលរដ្ឋ ត្រូវចូលរួមអនុវត្តសេចក្ដីណែនាំនេះ ប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៤

ខេត្តព្រះសីហនុ ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១

**អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ**

គួច_ចំរើន

**ចម្លងជូន៖**

-ក្រសួងមហាផ្ទៃ

-ក្រសួងសុខាភិបាល

«ដើម្បីគោរពជូនជ្រាប»

-ស្នងការដ្ឋាននគរបាលខេត្ត

-បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត

-មន្ទីរ អង្គភាពពាក់ព័ន្ធ

-រដ្ឋបាលក្រុង ស្រុក

«ដើម្បីអនុវត្ត»

-ឯកសារ-កាលប្បវត្តិ